# ស្ថានទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

## សុន្ទរកថារបស់ឯកឧត្តម ម៉ាសាហ្វុមី គូរ៉ូគី
## ឯកអគ្គរាជទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា
## ក្នុងពិធីសម្ពោធដាក់អោយប្រើប្រាស់អាគារសិក្សា នៅសាលាបឋមសិក្សាព្រែកព្នៅ

ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣

សូមក្រាបថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គ

សូមគោរព **ឯកឧត្តម កែប ជុតិមា** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ

សូមគោរពឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយស លោកស្រី និង អស់លោកទាំងអស់

ជាបឋម ខ្ញុំសូមធ្វើអភិវន្ទនកិច្ចចូលរួមរំលែកព្រះរាជមរណៈទុក្ខដ៏មហាក្រៀមក្រំជាមួយព្រះញាតិវង្សានុវង្ស រាជរដ្ឋាភិបាល និង ប្រជាជននៃព្រះរាជាណាចក្រកម្ពុជា ចំពោះការសោយព្រះទីវង្គតនៃ **ព្រះករុណា ព្រះបរមរតនកោដ្ឋ ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។**

ខ្ញុំសូមថ្លែងអំណរគុណដោយស្មោះសរចំពោះ **ឯកឧត្តម កែប ជុតិមា** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ចំពោះវត្តមានដ៏ឧត្តុង្គឧត្តមរបស់ឯកឧត្តមនៅក្នុងពិធីនេះ និងមន្ត្រី-រាជការទាំងអស់ចំពោះការរៀបចំអោយមានពិធីសម្ពោធដ៏ឧឡារិកនៅថ្ងៃនេះ។

ខ្ញុំមានសេចក្តីរីករាយដែលបានមកសាលាបឋមសិក្សាព្រែកព្នៅនៅថ្ងៃនេះ និងបានឃើញក្មួយៗសិស្សានុសិស្សទាំងអស់មានការសប្បាយរីករាយជាមួយនឹងអាគារសិក្សាថ្មីដែលជាអំណោយរបស់រដ្ឋាភិបាលជប៉ុន ។

កុមារគ្រប់ៗរូបមានសិទ្ធិទទួលបាននូវការអប់រំដែលជាសិទ្ធិជាមូលដ្ឋានរបស់មនុស្សជាតិ ហើយវាជាការសំខាន់ខ្លាំងណាស់ដើម្បីធានាថាមនុស្សគ្រប់ៗរូបត្រូវតែទទួលបាននូវការអប់រំស្មើភាពគ្នានៅទូទាំងប្រទេស ។ រាជរដ្ឋាភិបាលកម្ពុជា

តាមរយៈផែនការជាតិ “អប់រំសំរាប់ទាំងអស់គ្នា” បាន និងកំពុងខិតខំប្រឹងប្រែងធ្វើយ៉ាងណាដើម្បីអោយកុមារទាំងអស់ទទួលបាននូវការអប់រំកំរិតមូលដ្ឋាន ។ ទោះជាយ៉ាងណាក៏ដោយ ការកែលំអទាំងបរិមាណ និងគុណភាពអប់រំជាអភិក្រមដ៏វែងឆ្ងាយមួយដែលទាមទារអោយមានកិច្ចខិតខំប្រឹងប្រែងឥតឈប់ឈរ ។ រដ្ឋាភិបាលជប៉ុនបាន និងកំពុងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកែលំអវិស័យអប់រំតាមរយៈការជួយសាងសង់សាលាបឋមសិក្សា និង មធ្យមសិក្សា ក៏ដូចជាផ្តល់ការបណ្តុះបណ្តាលដល់គ្រូបង្រៀនជាដើម ។

ខ្ញុំបានទទួលព័ត៌មានថា ដោយសារមានការខ្វះខាតបន្ទប់រៀន សិស្សានុសិស្សចំនួន ៩ ថ្នាក់នៅសាលាបឋមសិក្សាព្រែកព្នៅត្រូវខ្ចីបន្ទប់សិក្សារបស់សាលាមធ្យមសិក្សាមួយដែលនៅក្បែរនេះដើម្បីប្រើប្រាស់ ។ ការសាងសង់អាគារសិក្សាថ្មីមួយខ្នងដែលមាន ៧ បន្ទប់ រួមទាំងបន្ទប់អនាម័យមួយខ្នងដែលមាន ៨ បន្ទប់ផងនេះ នឹងជួយអោយក្មួយៗសិស្សានុសិស្សទាំងអស់អាចសិក្សានៅក្នុងសាលាបឋមសិក្សារបស់ខ្លួននេះបានហើយ ។

ខ្ញុំសង្ឃឹមថា ក្មួយៗសិស្សានុសិស្សទាំងអស់នឹងខិតខំប្រឹងប្រែងរៀនសូត្រអោយបានកាន់តែប្រសើរជាងមុននៅក្នុងថ្នាក់រៀនថ្មីនេះ ។ សូមក្មួយៗរួមគ្នាជួយថែរក្សាថ្នាក់រៀន និងអាគារសិក្សានេះអោយបាននៅស្អាតល្អជានិច្ច និងប្រើប្រាស់បានយូរអង្វែង ទុកជានិមិត្តរូបមួយនៃចំណងមិត្តភាពរវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជា ។

ជាចុងក្រោយនេះ ខ្ញុំសូមសម្តែងនូវអំណរគុណដោយស្មោះសរចំពោះលោក-អ្នកទាំងអស់ដែលបានរួមចំណែកធ្វើអោយគំរោងការនេះអាចអនុវត្តទៅបានដោយរលូន ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា ។

សូមអរគុណ ។